# សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ៗបានបញ្ចប់ ខណៈពេលដែលទិវានីតិវិធីចាប់ផ្តើមកើតឡើង

*ដោយ ម៉ៃខល សាលីបា*

*ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

ក្នុងអំឡុងប៉ុន្មានសប្តាហ៍កន្លងទៅ អង្គសវនាការនៅក្នុងតុលាការកាត់ទោស កាំង ហ្គេចអ៊ាវ (ហៅ ឌុច) បានទទួលសក្ខីកម្មពីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៦នាក់ ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ បានតំណាងឲ្យជនជាតិកម្ពុជា និងជនជាតិបរទេស ។ អ្នកទាំងអស់នេះ បានបាត់បង់សមាជិកគ្រួសារនៅឯគុកទួលស្លែង (មន្ទីរស-២១) ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានធ្វើជាតំណាងឲ្យឪពុកម្តាយ បងប្អូនបង្កើត បងប្អូនជីដូនមួយ បងប្អូនសាច់ថ្លៃ និងកូនៗរបស់ជនរងគ្រោះ ។ មានក្មេងៗខ្លះមិនបានមានឱកាសស្គាល់ឪពុកម្តាយរបស់គេទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់ បានជាប់ឃុំឃាំង និងបញ្ជូនទៅកន្លែងកសាងខ្លួនក្នុងអំឡុងពេលនោះ ។ នៅក្នុងក្រុមដើមបណ្តឹងរដ្ឋប្បវេណីនេះ មានអ្នកខ្លះថែមទាំងបានចូលធ្វើបដិវត្តន៍ និងធ្វើការឲ្យរបបនេះ មុនពេលការចាប់ខ្លួន និងឃុំខ្លួនរបស់គេ ។

ទោះបីជាមានភាពខុសប្លែកគ្នាដ៏ច្រើនទាំងអស់នេះក៏ដោយ ក៏មានការយល់ចិត្តរួមគ្នាជាច្រើន ត្រូវបានបង្ហាញឲ្យឃើញដោយដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះផងដែរ ។ អ្នកទាំងអស់នេះ បានបង្ហាញខ្លួននៅមុខតុលាការកាត់ទោសដើម្បីស្វែងរកការពិត និងយុត្តិធម៌ ជាជាងស្វែងរកគំនុំ និងការសងសឹក ។ ពួកគេទាំងអស់ចង់ដឹងពត៌មានពីស្ថានភាពជុំវិញការស្លាប់របស់សមាជិកជាទីស្រឡាញ់របស់គេ ។ ពួកគេបានស្វែងរកសនិទានភាពមួយ ដើម្បីពន្យល់ពីការស្លាប់ទាំងអស់នេះ ទោះបីជាគ្មានហេតុផលត្រឹមត្រូវកើតមានឡើងក៏ដោយ ។ ខុសពីពាក្យចាស់ពោលថា ពេលវេលានឹងព្យាបាលរបួសនោះ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា ភាពឈឺចាប់ និងទុក្ខលំបាកវេទនារបស់គេ មានតែកើនឡើងជាមួយនឹងពេលវេលាទៅវិញ ។ ដូចដែល លោក ជីម សុធារ៉ា សាក្សីដ៏សំខាន់បានធ្វើកសិណសាក្សីនៅក្នុងអង្គសវនាការពេលព្រឹក ភាពឈឺចាប់ និងទុក្ខលំបាកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺជាក្រុមមនុស្សដែលមានលក្ខណៈដូចនឹងសង្គមកម្ពុជាទាំងមូលដែរ ។

# ប្រជាជនកម្ពុជានៅតែរងទុក្ខលំបាកពីរបួសផ្លូវចិត្ត

ជីម សុធារ៉ា បានឆ្លើយប្រាប់ពីបញ្ហារបួសផ្លូវចិត្តដែលជនរងគ្រោះរបស់របបខ្មែរក្រហមបានទទួលរង ។ ក្នុងនាមជាសាក្សីដ៏សំខាន់ លោកបានធ្វើសច្ចាប្រណិធានមុននឹងធ្វើកសិណសាក្សី ដោយគ្មានជាប់ពាក់ព័ន្ធនឹងភាគីណាសោះឡើយ ។ (មិនដូចដើមបណ្ដឹងរដ្ឋប្បវេណី សាក្សីសំខាន់ និងសាក្សីដែលមិនមានការយល់ដឹងច្រើន ត្រូវបានតម្រូវឲ្យធ្វើសច្ចាប្រណិធានមុនធ្វើកសិណសាក្សី) ។

ដំបូង លោកបានពន្យល់ថា ប្រជាជនកម្ពុជាមួយភាគធំបានរងរបួសផ្លូវចិត្តក្នុងអំឡុងពេល និងក្រោយពេលរបបគ្រប់គ្រងរបស់ខ្មែរក្រហម ។ ការរងទុក្ខលំបាកទាំងអស់នេះ គឺបណ្ដាលមកពីការបំផ្លិចបំផ្លាញប្រព័ន្ធសង្គមរបស់កម្ពុជា ។ លោកបានរៀបរាប់ពីវិធីដែលសាលារៀន មន្ទីរពេទ្យ និងស្ថាប័នផ្សេងៗទៀតត្រូវបានបំផ្លាញ ។ កូនក្មេងត្រូវបានបំបែកចេញពីឪពុកម្ដាយរបស់គេ ។ លើសពីនេះ ប្រជាជនកម្ពុជាទូទាំងប្រទេស ត្រូវបានបង្ខំឲ្យធ្វើការងារនៅក្នុងវាលស្រែក្នុងរយៈពេលដ៏យូរ ក្រោមស្ថានភាពដ៏លំបាកបំផុត ។ មនុស្សគ្រប់រូបរស់នៅក្នុងភាពភ័យខ្លាចរហូតក្នុងអំឡុងការគ្រប់គ្រងបួនឆ្នាំពេញរបស់ខ្មែរក្រហម ។ កត្តាទាំងអស់នេះហើយ ដែលបណ្ដាលឲ្យមានការរងជម្ងឺផ្លូវចិត្តរយៈពេលខ្លី និងរយៈពេលវែងរបស់សង្គមកម្ពុជា ។

ជាក់ស្ដែងជាងនេះ ការស្រាវជ្រាវលើប្រធានបទនេះ បានបែងថា ៤០ភាគរយនៃប្រជាជនកម្ពុជាបានជួបនឹងបញ្ហាសុខភាពសតិអារម្មណ៍ និងផ្លូវចិត្តពីកម្រិតស្រាលដល់កម្រិតធ្ងន់ ។ សព្វថ្ងៃនេះ ជនរងគ្រោះជាច្រើន មិនអាចផ្ចិតផ្ចង់ជាមួយនឹងកិច្ចការប្រចាំថ្ងៃរបស់គេបានឡើយ ។ ចំណែកឯអ្នកដទៃទៀត ប្រឈមមុខនឹងការយល់សប្ដិអាក្រក់ដែលកើតឡើងម្ដងទៀត ដោយឃើញខ្លួនគេត្រូវបានដេញតាមសម្លាប់ដោយពួកខ្មែរក្រហម ឬក៏សាច់ញាតិដែលស្លាប់ទៅហើយរបស់គេនោះយំស្រែកឲ្យជួយ ។ ជនរងគ្រោះជាច្រើន បានបាត់បង់ឆន្ទះរបស់ខ្លួនដើម្បីរស់នៅ និងបានចាត់ទុកការធ្វើអត្តឃាតជាមធ្យោបាយមួយដើម្បីគេចចេញពីភាពឈឺចាប់របស់គេ ។ របួសផ្លូវចិត្តគឺមិនមានព្រំដែនកំណត់ទេចំពោះមនុស្សជំនាន់ក្រោយដែលរួចផុតពីរបបខ្មែរក្រហមនេះ ប៉ុន្តែជាញឹកញាប់មានតែពេលវេលាទេ ដែលបន្តទៅឲ្យមនុស្សជំនាន់ក្រោយ ។

ជីម សុធារ៉ា បានចន្លុលបង្ហាញពីកត្តាជាច្រើនដែលអាចជួយធ្វើឲ្យរបួសផ្លូវចិត្តរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់គេមានភាពធូរស្រាល ។ បញ្ហាដ៏ចម្បងមួយកាលពីសាមសិបឆ្នាំកន្លងទៅនេះ គឺការខ្វះខាតសេវាកម្មថែទាំសុខភាព និងផ្នែកចិត្តសាស្ត្រឲ្យបានគ្រប់គ្រាន់ ។ សេវាកម្មទាំងនេះ មានសារសំខាន់ដ៏ចម្បងសម្រាប់ការជាសះស្បើយផ្លូវចិត្តដ៏ជោគជ័យរបស់ជនរងគ្រោះ ។ កត្តាដ៏សំខាន់មួយទៀតនៅក្នុងដំណើរការព្យាបាលរបួស គឺការសុំទោសដ៏ស្មោះត្រង់ និងពិតប្រាកដរបស់ជនជាប់ចោទដោយបង្ហាញពីវិប្បដិសារី ។ ដុយពី ឌុច ដែលបានទទួលស្គាល់ទំនួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មរបស់ខ្លួននោះ សញ្ញាណចន្លុលបង្ហាញទាំងអស់នេះ គឺថា ជនជាប់ចោទជាបន្តបន្ទាប់ដែលនឹងមកបង្ហាញខ្លួននៅមុខតុលាការកាត់ទោស នឹងមិនបង្ហាញវិប្បដិសារីដែលមានកម្រិតដូចគេទេ ។ ដើម្បីជួយសម្រាលរបួសផ្លូវចិត្តរបស់ជនរងគ្រោះ ខណៈពេលដែលជនជាប់ចោទដែលត្រូវទទួលខុសត្រូវបដិសេធលើឧក្រិដ្ឋកម្មរបស់ខ្លួននោះវាពិតជាមានសារសំខាន់ដែលថា តុលាការកាត់ទោសគួរតែបង្ហាញពីការពិតនៃប្រវត្តិសាស្ត្រ និងធ្វើឲ្យជនជាប់ចោទទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មរបស់គេ ។

ជាមួយគ្នានេះ ជីម សុធារ៉ា ក៏បានសិក្សាកាន់តែជ្រៅទៅក្នុងទស្សនៈដ៏ទូលំទូលាយនៃយុត្តិធម៌ ការអត់ឱនទោស និងការផ្សះផ្សារ ។ លោកបានពន្យល់ថា ទស្សនៈទាំងអស់នេះមានភាពទាក់ទងគ្នាទៅវិញទៅមក ។ ការពិត និងយុត្តិធម៌ គឺជាសមាសធាតុដែលមានមូលដ្ឋានដ៏សំខាន់ដែលត្រូវតែបង្កើតឲ្យមានឡើងមុននឹងជនរងគ្រោះខ្លះបានរៀបចំខ្លួនដើម្បីធ្វើការអត់ឱនទោស ។ ស្របពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើជាតំណាងឲ្យផ្នែកមួយនៃយុត្តិធម៌ដែលជានិមិត្តសញ្ញានោះ យន្តការដ៏សំខាន់មួយសម្រាប់ការផ្សះផ្សាជាតិត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយភាពលំបាកវេទនាផ្លូវចិត្តរបស់ប្រជាជនកម្ពុជាឲ្យបានសមរម្យ ។

## ***មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបដិសេធនឹងសេចក្តីជំទាស់របស់មេធាវីការពារក្តីពីពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី***

នៅក្នុងអង្គសវនាការពេលរសៀល អង្គជំនុំជម្រះសាលាដំបូង បានចាប់ផ្តើមស្តាប់សេចក្តីជំទាស់របស់មេធាវីការពារក្តីចំពោះភាពដែលអាចអនុញ្ញាតបាននៃពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដំបូងក្រុមមេធាវីការពារក្តីអះអាងថា ភាពជាប់ពាក់ព័ន្ធនឹងមន្ទីរស-២១របស់ជនរងគ្រោះ មិនបានបង្ហាញពីទំនាក់ទំនងដ៏ចាំបាច់ទេ ។ ទីពីរ ពួកគេបានអះអាងថា ពាក្យស្នើសុំជាច្រើនមានការខ្វះខាតនូវភស្តុតាង

ជាឯកសារ ដើម្បីបង្ហាញថាជនរងគ្រោះពិតជាត្រូវបានជាប់ឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១មែន ។ ជាចុងក្រោយ ក្រុមមេធាវីការពារក្តី បានអះអាចថា ពាក្យស្នើសុំដូចគ្នាជាច្រើនទាំងអស់នេះ ខ្វះខាតនូវភស្តុតាងជាឯកសារ ដើម្បីបង្ហាញថាដើមបណ្តឹងរដ្ឋប្បវេណីមានជាប់ពាក់ព័ន្ធនឹងជនរងគ្រោះនៅក្នុងបរិបទដែលបានចាត់ទុកថាជាការពិត ។

មុននឹងអង្គសវនាការចាប់ផ្តើមស្តាប់សក្ខីកម្មសំខាន់ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី អាឡាំង វែនណឺ បានបដិសេធ និងអះអាងថា មេធាវីការពារក្តី មិនអាចជំទាស់នឹងពាក្យស្នើសុំទាំងអស់នេះបានទៀតទេ ។ នេះបង្កឲ្យមានជាការវែកញែកផ្នែកនីតិវិធីដ៏ក្តៅគគុកនិងមានរយៈពេលយូរវវាង អាឡាំង វែនណឺ និងមេធាវីការពារក្តីអន្តរជាតិ ហ្រ្វង់ស្វ័រ រ៉ូ ។ អាឡាំង វែនណឺ បានអះអាងថា ភាពដែលអាចទទួលយកបានរបស់ពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺត្រូវបានគ្រប់គ្រងដោយវិធានផ្ទៃក្នុងទី២៣ និងទី៨៣ ដែលបានចែងថា សេចក្តីជំទាស់ទាំងអស់ត្រូវតែធ្វើឡើងនៅក្នុងអំឡុងអង្គសវនាការជំនុំជម្រះដំបូង ។ លោកបានរំឭកចៅក្រមថា ក្នុងអំឡុងអង្គសវនាការជំនុំជម្រះដំបូងពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីត្រូវបានជំទាស់ ហើយសេចក្តីជំទាស់មួយនៅក្នុងចំណោមសេចក្តីជំទាស់ទាំងអស់ត្រូវបានបន្តធ្វើឡើងរហូត ។ ជាមួយគ្នានេះ លោកក៏បានទទួលស្គាល់ពីអំណាចនៃសេចក្តីសម្រេចរបស់ចៅក្រម តាមមាត្រាទី១០០ ដើម្បីស្តាប់ពីការវែងគំនិតគ្នាលើភាពដែលអាចទទួលយកបានគ្រប់ពេលទាំងអស់ រហូតដល់ពេលសេចក្តីសម្រេចត្រូវបានផ្តល់ឲ្យ ។ យ៉ាងណាមិញ អាឡាំង វែនណឺ ក៏បានអះអាងថា សេចក្តីសម្រេចនេះគឺគ្មានថ្ងៃនឹងអនុញ្ញាតឲ្យមេធាវីការពារក្តីលើកឡើងពីសេចក្តីជំទាស់ចំពោះពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយខ្លួនឯងនោះបានឡើយ ។

ហ្រ្វង់ស្វ័រ រ៉ូ បានឆ្លើយតបទៅវិញថា ការបដិសេធរបស់ អាឡាំង វែនណឺ មានភាពយឺតយ៉ាវ ហើយគួរតែត្រូវបានធ្វើឡើងកាលពីសប្តាហ៍មុន នៅពេលដែលតុលាការសុំឲ្យមេធាវីការពារក្តីរៀបចំសេចក្តីសន្និដ្ឋានរបស់ខ្លួនទាក់ទិននឹងពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ បន្ថែមលើនេះ ក្នុងអំឡុងអង្គសវនាការជំនុំជម្រះដំបូង ពាក្យស្នើសុំខ្លះត្រូវបានទទួលយកកាលពីមុនរួចហើយ ហើយមេធាវីការពារក្តីទទួលបានសិទ្ធិជំទាស់នឹងពាក្យស្នើសុំទាំងអស់នេះ ។ ជាចុងក្រោយ មេធាវីការពារក្តីបានអះអាងថា វាគឺជាការធម្មតាក្នុងការឆ្លើយតបនឹងសំណូមពរដោយផ្ទាល់មួយពីអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបានធ្វើឡើងតាមអំណាចចេញសេចក្តីសម្រេចតាមមាត្រាទី១០០ ។

ចៅក្រម មិនបានផ្តល់ឲ្យដឹងឲ្យច្បាស់លាស់ពីសេចក្តីសម្រេចរបស់ខ្លួនចំពោះបញ្ហាផ្នែកនីតិវិធី ដែលនឹងចោទជាផលវិបាកដ៏ចម្បងជាច្រើននោះទេ។ ដំបូង ប្រសិនបើតុលាការបន្តដំណើរការនីតិវិធីតាមសេចក្តីដីទាស់របស់មេធាវីការពារក្តី និងសម្រេចថាពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនមិនអាចទទួលយកបាន នោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ នឹងមានសិទ្ធិតាមវិធានផ្ទៃក្នុង ដើម្បីស្នើសុំដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការដំបូង។ ទោះបីជាមានឱកាសធ្វើការស្នើសុំក៏ដោយ ក៏សេចក្តីសម្រេចប្រភេទនេះដែលធ្វើឡើងដោយយឺតយ៉ាវនៅក្នុងអង្គជំនុំជម្រះ អាចនឹងក្លាយជាមានភាពខូចខាតដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលរងផលប៉ះពាល់។ អស់រយៈពេល៦ខែដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសិទ្ធិចូលរួមកដើម្បីធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ហើយពួកគេក៏មានចំណាប់អារម្មណ៍ផ្ទាល់ខ្លួននៅក្នុងលទ្ធផលរបស់តុលាការ។

ការបដិសេធ និងការវែកញែកដ៏យូរនេះ អាចចាត់ទុកថាជាយុទ្ធសាស្ត្រការប្តឹងដ៏ល្អមួយ បើទោះបីជាតុលាការសម្រេចថាស្តាប់ពីសេចក្តីដីទាស់ ពីព្រោះថា ចៅក្រមអាចធ្វើឲ្យមានភាពងាយស្រួលដល់ការចាប់ផ្តើមនៃការបង្ហាញភស្តុតាង ខណៈពេលដែលកំពុងធ្វើការវាយតម្លៃលើពាក្យស្នើសុំនីមួយៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទំនងជាមានការព្រួយបារម្ភថា ពួកគេមិនអាចទទួលបាននូវឯកសារដែលពាក់ព័ន្ធនឹងមន្ទីរស-២១ជាច្រើន ពីព្រោះថាកំណត់ត្រាសំខាន់ៗ មិនបានរក្សាទុកនៅក្នុងគុកឡើយ ហើយចំណែកឯកសារខ្លះទៀតនៅមន្ទីរស-២១ ត្រូវបានបំផ្លាញចោល។ ជាការពិត ការព្រួយបារម្ភបែបទាំងនេះ គឺជាមូលហេតុខ្លះដែលតុលាការនេះ រួមទាំងតុលាការអន្តរជាតិដទៃទៀត បានសម្រួលច្បាប់ភស្តុតាងរបស់ខ្លួន។ (ឧទាហរណ៍ តុលាការនេះ មិនបានធ្វើការហាមឃាត់ភាពដែលអាចទទួលយកបាននៃភស្តុតាងដែលជាពាក្យចចាមអារ៉ាមនោះទេ។)